ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋបាលជលផល**

លេខ: ២៤០៥ ជផ

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ សំណើសូមជ្រើសរើសកំពង់ផែ **ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** (L.Y.P GROUP CO.,LTD) សម្រាប់នាវានេសាទ ឬនាវាពាក់ព័ន្ធនឹងការនេសាទបរទេស ចូលចត ឡើងផល ផលិតផលជលផល និងប្រើសេវាកំពង់ផែ។

**យោង** ៖- ព្រះរាជក្រមលេខ នស/រកម/០៧១៩/០១០ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀង ស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

- លិខិតលេខ៨៩៥៦ កបទ-សរអ/ច្បក១ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ស្តីពីលិខិតុបករណ៍ចូលជារដ្ឋភាគីនៃកិច្ចព្រមព្រៀង ស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃកិច្ចព្រមព្រៀង ស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (PSMA) របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩។ បច្ចុប្បន្នប្រទេសជាសមាជិកមានចំនួន៧២ ក្នុងនោះនៅតំបន់អាស៊ីអាគ្នេយ៍មានចំនួន៦ប្រទេស គឺកម្ពុជា មីយ៉ាន់ម៉ា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាម បានចូលជាភាគីអនុវត្តកិច្ចព្រមព្រៀង PSMA។ អនុលោមតាមមាត្រា៧នៃកិច្ចព្រមព្រៀង ភាគីនីមួយៗ ត្រូវកំណត់ និងផ្សព្វផ្សាយអំពីកំពង់ផែសម្រាប់ឱ្យនាវាបរទេស អាចស្នើសុំចូលចត។ ភាគីនីមួយៗ ត្រូវផ្តល់បញ្ជីឈ្មោះកំពង់ផែដែលបានកំណត់ទៅអង្គការ FAO ដើម្បីផ្សព្វផ្សាយជាសាធារណៈ។

រដ្ឋបាលជលផល និងអង្គការ FAO បានពិនិត្យ សិក្សា និងវាយតម្លៃ កំពង់ផែ **ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** (L.Y.P GROUP CO.,LTD) ដែលមានទីតាំងនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង មានលក្ខណៈសមស្រប សម្រាប់នាវាបរទេសស្នើសុំចូលចត ឡើងផល ផលិតផលជលផល និងប្រើសេវាកំពង់ផែ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ អង្គារ ០៤ រោច ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០២២

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**ពុំ សុថា**

**ចម្លងជូន៖**
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន៖អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ /Fax: (855) 23 215 470 www.fia.gov.kh
Address #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh capital, Cambodia, P.O.Box 582 /Fax: (855) 23 215 470 www.fia.gov.kh